# របាំកួយស្ងដែក

ប្រទេសកម្ពុជា មានជនជាតិដើមភាគតិចជាច្រើនដែលរស់នៅតាមតំបន់ភ្នំ និងខ្ពង់រាបជាច្រើនសតវត្សមកហើយ។ ជនជាតិកួយច្រើនក្រុម មានកួយដែក កួយដំរី កួយនត្រា កួយអន្ទរ កួយនរើ និងកួយគ្រុល រស់នៅក្នុងខេត្តពោធិសាត់ បាត់ដំបង កំពង់ធំ ព្រះវិហារ ឧត្តរមានជ័យ បន្ទាយមានជ័យ សៀមរាប ក្រចេះ និងស្ទឹងត្រែង មានវប្បធម៌ ទំនៀមទម្លាប់ ប្រពៃណី និងជំនឿ ដែលគេបានថែរក្សារហូតមកទល់នឹងពេលបច្ចុប្បន្ននេះ។[១]

លោកតា លោកយាយចាស់ៗនៅក្នុងខេត្តកំពង់ធំនិងខេត្តព្រះវិហារ បានមានប្រសាសន៍អំពីប្រវត្តិរបស់ជនជាតិកួយ ក្នុងការស្ងដែក ដូចជាភូមិរំចេក ភូមិព្រៃកណ្ដាល ភូមិថ្នល់កោង ឃុំរំដោះ ស្រុករវៀង និងឃុំរមណីយ៍ជាដើម។ល។ ពិធីស្ងដែកមានតាំងពីមុនសម័យអង្គរមកម្ល៉េះ ចាប់ពីសតវត្សទី១ ក្នុងអំឡុង សម័យនគរភ្នំ សម័យចេនឡា និងសម័យអង្គរ ក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី២ (៨០២-៨៥០)។ ស្របពេលជាមួយគ្នានេះ ក៏មានសង្គ្រាមជាមួយសត្រូវជាញឹកញាប់ ហើយយើងមិនទាន់មានអាវុធយុទ្ធភ័ណ្ឌសម្បូណ៌បែបនៅឡើយ។ តែដោយអំណោយផល ប្រទេសយើងសម្បូណ៌ទៅដោយសម្បត្តិធម្មជាតិរ៉ែជាច្រើន ដូចជារ៉ែដែក នៅម្ដុំភ្នំដែក គឺភ្នំរយោល មានព្រៃខ្ពស់ៗ កម្ពស់ប្រមាណជិត១០០ម៉ែត្រ មានភ្នំតូចៗនៅក្បែរនោះទៀត មានចម្ងាយប្រមាណ៤០គីឡូម៉ែត្រ ប៉ែកខាងជើងខេត្តកំពង់ធំបច្ចុប្បន្ន និងស្ថិតក្នុងស្រុករវៀង ខេត្តព្រះវិហារ។[២]

នៅត្រង់កន្លែងគេស្ងដែក គេជីកដីលុងធ្វើជើងក្រានឡមួយយ៉ាងធំ មានចង្អូរបញ្ចេញពីឡសម្រាប់បង្ហូរដែក។ នៅផ្នែកជើងក្រានឡ មានស្នប់ដាន់សប់ឈើរចំនួន៣ ឬ ៥ទៅតាមឡតូចឬធំ។ បើគ្មានស្នប់ទេ គេបក់នឹងក្រណាត់បាវ ដោយគេគាបសង្កត់ក្បាលបាវ វាយឃ្នាបជាប់នឹងដីមាត់រន្ធខ្យល់ រួចគេអង្គុយបក់បញ្ចូលខ្យល់ទៅតាមរន្ធបញ្ចូលនៅក្នុងឡ។ បើគេប្រើស្នប់វិញ គេយកដីឥដ្ឋ មានរាងស៊ីឡាំង ពាសស្បែកគោនៅពីលើ។ នៅលើស្បែកគោនោះ គេចាប់ទំពក់ ថ្ពក់ជាប់នៅដងសន្ទូច ដើម្បីទាញឱ្យប៉ោងយកខ្យល់ ហើយគេដាន់

[១] ជួន ណាត ១៩៦៧: ៤៦; ង៉ួន សំអាត ២០១២: ៦; Diffloth 2011: 12, 14

[២] ង៉ួន សំអាត ២០១២: ១

អត្ថបទដោយ៖

ស្មើគ្នា។ ឯរន្ធនោះ គេជីករូងដីឱ្យឆ្ងាយពីឡមានចម្ងាយប្រមាណ៣ម៉ែត្រ។ នៅឡស្ងដែកនីមួយៗ មានរន្ធខ្យល់បក់ ៣ទៅ៤ ដូចប្រើស្នប់ជាន់ដែរ។

នៅក្នុងឡ គេចាក់ថ្មដែលមានជាតិរ៉ែដែក។ តាមការដឹងនិងការអនុវត្តក្នុងការដុតដែកធ្វើឧបករណ៍ប្រើប្រាស់ គឺគេយកដើមទ្រាស ឬដើមម្រក្ស មកប្រើក្នុងការរំលាយដែក ទើបមានកំដៅលើសផុតពីធ្យូងនៃដើមឈើដទៃទៀត។ គេយកទៅដាក់តាមស្រទាប់ៗជាមួយនឹងថ្មនិងអុសធ្យូង មុននឹងដុតភ្លើង បក់ ឬសប់ ធ្វើឱ្យឡនោះឆេះ គេត្រូវរៀបរណ្ដាប់បញ្ចូលមេស្នឹងសិន។ ការស្ងដែកត្រូវមានមេស្នឹងឬឆាយ (អ្នកចូលរូប) ជាចាំបាច់ព្រោះគាត់ជាមនុស្សសំខាន់ខាងផ្លូវក្នុងនិងផ្លូវក្រៅ។ មេស្នឹងត្រូវមានតំណមជាច្រើន ដូចជាត្រូវហូបបាយគេយកគ្រាប់ស្រូវដែលបកដោយដៃស្រីក្រមុំ។ ឯរណ្ដាប់វិញត្រូវមានស្រា បង្អែម ទៀន និងធូប ដាក់មួយស្លកនៅមុខមេស្នឹង ដោយមានស្នំប្រុសអង្គុយអមមេស្នឹងនៅខាងស្ដាំមួយជួរ ស្នំស្រីអមមេស្នឹងនៅខាងឆ្វេងមួយជួរ។[៣]

មេស្នឹងនោះអង្គុយពែនភ្នែននៅកណ្ដាល ជូតក្បាលនឹងសំពត់ស មុននឹងចាប់ច្រៀងបទបញ្ចូលរូប ទាំងស្នំទាំងមេស្នឹងត្រូវឱនក្បាលក្រាបសំពះគ្រឿងសក្ការៈបូជា បីដងសិន រួចស្នំចាប់ច្រៀងនិងទះដៃបន្ទរទៅតាមទំនុកបទភ្លេង។ រីឯភ្លើងដើងក្រានឡ ក៏ចាប់ដុតឡើងស្មើៗគ្នា។ អ្នកសប់ស្នប់ឬអ្នកបក់ខ្យល់ ក៏ចាប់ធ្វើឡើងព្រមៗគ្នាទាំងអស់។

គេសប់ ឬបក់ទៅតាមទំនុកចម្រៀង។ លុះខ្មោចចូលរូបមេស្នឹងស៊ប់ហើយ មេស្នឹងក៏ងើបឡើងឈរ កាន់ដាវត្រីរាំតាមបែបបទ ឯស្នំក៏ក្រោកឈររាំជាមួយដែរ និងរាំជុំវិញឡទៀតផង។ ការសប់ស្នប់ ឬការបក់ខ្យល់ បញ្ចូលទៅក្នុងឡនោះ ជួនកាលគេធ្វើមួយៗ ជួនកាលគេធ្វើញាប់ទៅតាមសម្លេងច្រៀង និងសម្លេងទះដៃរបស់ស្នំ។ គេធ្វើរបៀបនេះរហូតដល់ដែកនោះរលាយហូរចេញពីឡ ទើបស្នំឈប់ច្រៀង ឯខ្មោច ព្រាយក៏ចេញពីរូបស្នឹង។ អ្នកសប់ ឬអ្នកបក់នៅតែសប់ បក់បង្ហូរដែកលុះត្រាតែអស់ជាតិដែកលែងហូរចេញពីឡទើបឈប់។ ការធ្វើឡ និងរបៀបស្ងដែកនេះមានលក្ខណៈខុសៗគ្នា ពីកន្លែងមួយទៅកន្លែងមួយ។ ឯការរៀបចំពិធីបញ្ចូលស្នឹង ក៏មានលក្ខណៈខុសៗគ្នាខ្លះដែរ។ ការស្ងដែកគេធ្វើមួយឆ្នាំម្ដង នៅខែបុស្សឬមាឃ ក្រោយពីការប្រមូលផលស្រូវរួច។

---

[៣] ង្វៀន សំអាត ២០១២: ៥-៦

អត្ថបទដោយ៖

សូមបញ្ជាក់ថា នៅក្នុងចម្រៀងភ្លេងការខ្មែរយើង ក៏មានបញ្ជាក់អំពីពាក្យថា «ដែកកំពង់ស្វាយ»។ នេះហើយជាទីតាំងកន្លែងធ្វើដែករបស់ជនជាតិកួយដែរ។ ភាគច្រើន គេប្រើប្រាស់បទភ្លេងប្រពៃណីដូចខ្មែរយើងដែរ ជួនកាលគេប្រើស្គរធំ និងគងដោះ ជាមួយទៀតផង។[៤]

ជនជាតិដើមភាគតិចកួយ មានរបាំមួយចំនួន ដូចជារបាំវាយកួយ (ដែលគេហៅថារបាំវាយខែល ឬរបាំប្រវាយកួយដែរទៅតាមតំបន់ មាននៅខេត្តស្ទឹងត្រែងជាដើម) របាំតាទើត ជារបាំបុរាណនៅខេត្តស្ទឹងត្រែង របាំកួយរុំចន្ទុះរបស់មន្ទីរវប្បធម៌ខេត្តកំពង់ធំ និងរបាំកួយស្ទូដែកដែលទទួលបានជាជ័យលាភីលេខ១ នៅក្នុងមហោស្រពសិល្បៈនៃទិវាវប្បធម៌ជាតិ៣មីនាលើកទី១៨ ឆ្នាំ២០១៦។

ព័ត៌មានសំខាន់នៅក្នុងអត្ថបទនេះ ផ្ដោតពិសេសទៅលើ របាំកួយស្ទូដែក ឬបញ្ជាន់សន្ទុងសម្រាប់ពេលសម្ដែងរបាំ ដែលតម្លើងនិងបង្កើតដោយលោកគ្រូ ផ្លូន សំអាត នៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈ។ របាំស្ទូដែក ជារបាំមួយរបស់ជនជាតិកួយនៅក្នុងខេត្តកំពង់ធំ និងព្រះវិហារ។ របាំនេះត្រូវបានគេបង្កើតឡើងដើម្បីបង្ហាញអំពីវីរៈភាព របស់ជនជាតិកួយដែលចេះវិធីស្ទូដែក តាំងពីសម័យដើមយូរលង់ណាស់មកហើយ។ នេះក៏ជាការបង្ហាញឱ្យឃើញថាបងប្អូនជនជាតិដើមភាគតិចកួយ ធ្លាប់មានឈ្មោះល្បី រហូតដល់មានប្រវត្តិទាក់ទងយ៉ាងជិតស្និទ្ធជាមួយនឹងរាជការខ្មែរសម័យបុរាណ ដោយសារការស្ទូដែកនេះឯង។

របាំកួយស្ទូដែក ចែកជាបីឈុត៖

ឈុតទី១៖ ដកស្រង់បង្ហាញអំពីរូបភាពចេញពីរូបចម្លាក់ចម្លាំងលើជញ្ជាំងប្រាសាទបាយ័ន

ឈុតទី២៖ ការសែនព្រេន ក្នុងពិធីប្រមូលព្រលឹង

ឈុតទី៣៖ ការដំដែកដើម្បីផលិតឧបករណ៍ប្រើប្រាស់ជាតិពន្ធុផ្សេងៗ ដូចជាសិប្បកម្មសម្រាប់កសិកម្មជាដើម។

[៤] ផ្លូន សំអាត ២០១២: ៦

អត្ថបទដោយ៖

# ឯកសារពិគ្រោះ

ង៉ួន សំអាត. (២០១២). *ប្រវត្តិសង្ខេប ក្ងួយស្វដែក ខេត្តកំពង់ធំ-ខេត្តព្រះវិហារ*. ភ្នំពេញ:
សមាគមវប្បធម៌ខ្មែរ។

ជួន ណាត. (១៩៦៧). *វចនានុក្រមខ្មែរ*. ភ្នំពេញ: ពុទ្ធសាសនបណ្ឌិត្យ។

*បញ្ជីឈ្មោះ ខេត្ត ក្រុង ឃុំ សង្កាត់ ទូទាំងប្រទេសកម្ពុជា*. (២០០៦). ភ្នំពេញ:
គណ:កម្មាធិការជាតិរៀបចំការបោះឆ្នោត។

ពិន សុផាត. (២០០៧). *ក្ងួយដែកភូមិរំចេក ខេត្តព្រះវិហារកាលដើមកំពង់ធំ*. សារណា
បញ្ចប់បរិញ្ញាបត្របុរាណវិទ្យា សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ។

ហ្កេរ៉ាំង ម៉ាត្យឺ. (២០០៤). «អំពីករណីមួយរវាងឧកញ៉ានរេន្ទ្រសេនា អេក និងព្នងម្នាក់ឈ្មោះ
អង្កៀត ក្នុងឆ្នាំ គ.ស. ១៨៩១,» *សិក្សាចក្រ*, (លេខ៦), ទំព័រ៧៥-៨២។

*ឥសានបុរៈ ឬ សម្បូណ៌ព្រៃគុកៈ ពីសតវត្សទី៦-៧ នៃគ.ស*. (១៩៩៩). ភ្នំពេញ:
ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ។

Bourdier, Frederic. (2009). "Inter-ethnic Relationships and Specificity of Indigenous Populations
in Cambodia," *Ethnic Groups in Cambodia*. Phnom Penh: Center for Advanced Study, pp. 284-335.

Diffloth, Gérard. (2011). *Kuay in Cambodia: A Vocabulary with Historical Comments*. Phnom
Penh: Tuk Tuk Editions.

Dupaigne, Bernard. (1987). *Les Maitres du Fer et du Feu: Étude de la Métallurgie du Fer Chez
les Kouys du Nord du Cambodge dans le Contexte Historique et Ethnographique de l'Ensemble Khmer*, 4 Tomes. Thèse pour le Doctorat.

Grainger, Matthew. (July 28-August 10, 1995). "Government Approves Study of Ethnic Minorities," *Phnom Penh Post*, p. 8.

Sam, Chan Moly, Nguon, Sam Ath, and Sam, Sam-Ang. (1998). *Khmer Folk Dance* (2nd ed.). Washington, DC: Cambodian Network Council.

*អត្ថបទដោយ៖*

អត្ថបទដោយ៖